សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ
និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធគម្រោងសាងសង់មជ្ឈមណ្ឌលសិល្បៈក្បាច់គុនបុរាណកម្ពុជា-ជប៉ុននៅភ្នំពេញ
១២ ធ្នូ ២០១៥

- **សូមគោរព ឯកឧត្តម ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
- **សូមគោរព លោក ណាំង វ៉ារុធ ប្រធានសមាគមអៃគីដូកម្ពុជា**
- **សូមគោរព អស់លោក លោកស្រីទាំងអស់ជាទីមេត្រី!**

សេចក្ដីសោមនស្សរីករាយថ្ងៃនេះខ្ញុំមានដែលបានមកចូលរួមក្នុងពិធីសម្ពោធមជ្ឈមណ្ឌលសិល្បៈក្បាច់គុនបុរាណកម្ពុជា-ជប៉ុននៅភ្នំពេញ˝ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ជាបឋម ខ្ញុំសូមសម្ដែងនូវការដឹងគុណយ៉ាងស្មោះសរចំពោះសមាជិករបស់សមាគមអៃគីដូកម្ពុជាទាំងអស់ ដែលបានខិតខំប្រឹងប្រែងអនុវត្តគម្រោងនេះ។

គម្រោងនេះ គឺដើម្បីលើកស្ទួយសិល្បៈក្បាច់គុនបុរាណជប៉ុននៅក្នុងប្រទេសកម្ពុជា ដោយធ្វើការសាងសង់មជ្ឈមណ្ឌលចំនួនពីរជាន់សម្រាប់ការបណ្ដុះបណ្ដាលជាប្រចាំ និងជាកន្លែងសម្រាប់ធ្វើការប្រកួតជាផ្លូវការផងដែរ។ មជ្ឈមណ្ឌលថ្មីនេះ នឹងផ្ដល់ជូននូវការបណ្ដុះបណ្ដាលដ៏ល្អប្រសើរសម្រាប់សមាគមសិល្បៈក្បាច់គុនជាច្រើននៅក្នុងប្រទេសកម្ពុជារួមមាន៖ សមាគមនអៃគីដូកម្ពុជា សហព័ន្ធល្បុក្កតោកម្ពុជា សហព័ន្ធគូបូដុ និងជូដូកម្ពុជា និងកេនដូក្លឹបកម្ពុជា។ គម្រោងនេះ ត្រូវបានរំពឹងថាមជ្ឈមណ្ឌលសិល្បៈក្បាច់គុនបុរាណថ្មីនេះ នឹងក្លាយជាកន្លែងដែលមានសារៈសំខាន់សម្រាប់អភិវឌ្ឍវិស័យសិល្បៈក្បាច់គុនជប៉ុន ដែលមានការទាក់ទាញយ៉ាងច្រើនពីសំណាក់អ្នកចូលចិត្តហ្វឹកហាត់ក្បាច់គុននានា។

សិល្បៈក្បាច់គុនជប៉ុន មិនត្រឹមតែជាក្បាច់គុនសម្រាប់បណ្ដុះបណ្ដាលទាំងកាយសម្បទារបស់អ្នកហ្វឹកហាត់ប៉ុណ្ណោះទេ ថែមទាំងជួយបណ្ដុះនូវស្មារតី ហើយបានឆ្លុះបញ្ចាំងពីសីលធម៌ និងការគួរសមខិនលំទោនរបស់អ្នកហ្វឹកហាត់ផងដែរ។ ខ្ញុំសង្ឃឹមថា ការបណ្ដុះស្មារតីដល់ក្មេងជំនាន់ក្រោយនេះ គឺជាការអភិវឌ្ឍធនធានមនុស្ស និងកសាងប្រទេសជាតិអោយមានការរីកចំរើនទ្វេដង។

ខ្ញុំសង្ឃឹមថា មជ្ឈមណ្ឌសិល្បៈក្បាច់កុនបុរាណនេះ នឹងក្លាយជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពដ៏យូរអង្វែងរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងត្រូវបានថែទាំអោយនៅគង់វង្សល្អ។

ជាចុងក្រោយនេះ ខ្ញុំសូមសម្ដែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកក្នុងការអនុវត្តនូវគម្រោង និងការសាងសង់នេះអោយបានបញ្ចប់ទៅដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**